**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក-អជសង

ភាគីដាក់ឯកសារ៖ សហមេធាវីការពារក្តីលោក អៀង សារី

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **អង់គ្លេស**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សាធារណៈ / Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ដែលដាក់រួមជាមួយនឹងបញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន៨០**

---

**ដាក់ដោយ៖**

**សហមេធាវីការពារក្តី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**ផ្ញើជូន៖**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម យូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបម្រុង យូរ ឧត្តរា

ចៅក្រមបម្រុង Claudia FENZ

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 08 / 02 / 2011
ម៉ោង (Time/Heure): 10:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លោក អៀង សារី តាមរយៈមេធាវីការពារក្តីរបស់ខ្លួន ("ក្រុមមេធាវីការពារក្តី") សូមឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ដែលដាក់អមជាមួយនឹងបញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន៨០ "សំណើ"[1]។ សំណើបានលើកឡើងនូវបញ្ហាចំនួនប្រាំមួយ ដែលត្រូវដោះស្រាយមុនពេលជំនុំជម្រះ៖

ក. ពេលវេលាសមរម្យតាមសមាមាត្រដើម្បីសួរសាក្សី[2]

ខ. ការប្រើប្រាស់ចម្លើយរបស់សាក្សីនានា ដោយមិនបានស្តាប់ចម្លើយសាក្សីពាក់ព័ន្ធ[3]

គ. ការស្តាប់ចម្លើយសាក្សីនានា ដែលមានឈ្មោះនៅក្នុងឧបសម្ព័ន្ធ៥[4]

ឃ. វចនាសម្ព័ន្ធ និងការធ្វើបទបង្ហាញភស្តុតាង[5]

ង. លទ្ធភាពក្នុងការកោះហៅសាក្សីបន្ថែមក្នុងអំឡុងពេលជំនុំជម្រះ[6] និង

ច. លទ្ធភាពកោះហៅសាក្សីនានា ដែលសហចៅក្រមស៊ើបអង្កេតនៅមិនទាន់បានធ្វើការស្តាប់ចម្លើយ[7]

មេធាវីការពារក្តីស្នើសុំឱ្យបើកសវនាការសួរដេញដោលផ្ទាល់មាត់ ដើម្បីដោះស្រាយបញ្ហាទាំងនេះ ។ ការស្នើសុំនេះមានភាពសមស្របសម្រាប់កិច្ចប្រជុំរៀបចំសវនាការដែលនឹងធ្វើឡើងនៅខែមីនា ឬខែមេសា ឆ្នាំ២០១១ ខាងមុខ[8]។

## I. ឧឡឹករណ៍

### ក. ពេលវេលាសមរម្យតាមសមាមាត្រសម្រាប់សួរសាក្សី

---

[1] *រឿងក្តី នួន ជា* សំណុំរឿងលេខ០០២-១៩-០៩-២០០៧-អវតក/អជសង បញ្ជីសាក្សី និងភាគីដើមបណ្តឹងរដ្ឋប្បវេណីរបស់សហព្រះរាជអាជ្ញា តាមវិធាន៨០ រួមទាំងឧបសម្ព័ន្ធសម្គាល់១,២,៣,៣ក,៤ និង៥ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ ឯកសារ E9/4.2 ERN: 00640732-00640736។

[2] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ៧។

[3] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ១០។

[4] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ១១។

[5] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ១៥-២១។

[6] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ១០-១២។

[7] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ១៣។

[8] សារអេឡិចត្រូនិកផ្ញើពី Susan Lamb អ្នកសម្របសម្រួលជាន់ខ្ពស់ផ្នែកតុលាការ ទៅកាន់ក្រុមមេធាវីការពារក្តី អៀង សារី កម្មវត្ថុ៖ ការប្រាស្រ័យទាក់ទងទៅនឹងភាគីក្នុងនាមអង្គជំនុំជម្រះសាលាដំបូង-ក្រុមមេធាវីការពារក្តី អៀង សារី, ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១។

1. នៅក្នុងកថាខណ្ឌ៧ ក.ស.ព លើកអំណះអំណាងថា ការប៉ាន់ប្រមាណអំពីពេលវេលា ត្រូវបានកំណត់ដោយឈរលើមូលដ្ឋានដែលថា សហព្រះរាជអាជ្ញាអាចសួរសំណួរទៅអ្នកជំនាញ ដើមបណ្ដឹងរដ្ឋប្បវេណី ឬសាក្សី យ៉ាងហោចណាស់ក៏ត្រូវចំណាយមួយភាគបីនៃពេលវេលាដែលគេប៉ាន់ប្រមាណសម្រាប់ការផ្ដល់សក្ខីកម្មទាំងមូល។ នេះមានន័យថា ពីរភាគបីនៃពេលវេលានៅសល់ ត្រូវបែងចែករវាងអង្គជំនុំជម្រះសាលាដំបូង ដើមបណ្ដឹងរដ្ឋប្បវេណីប្រហែលជា ២.១២៣ រូប និងក្រុមមេធាវីការពារក្ដីទាំងបួនក្រុម។ ទោះបីជាអាចសន្មតថា អង្គជំនុំជម្រះសាលាដំបូងភាគច្រើនទុកការសួរសំណួរសំខាន់ៗឲ្យទៅភាគីនានាក្ដី ដែលករណីនេះមិនទាន់ត្រូវបានពិភាក្សា ឬដោះស្រាយនៅឡើយទេ និងទោះបីជាអាចសន្មតថា មានតែមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីតែមួយរូបប៉ុណ្ណោះ ដែលនឹងសួរសំណួរទៅអ្នកជំនាញ ដើមបណ្ដឹងរដ្ឋប្បវេណី ឬសាក្សីនីមួយៗ ដែលករណីនេះហាក់ដូចជាមិនមែនជាលក្ខខណ្ឌតម្រូវផ្អែកតាមវិធានផ្ទៃក្នុងទេ ក៏មេធាវីការពារក្ដីទាំងបួនក្រុម មិនអាចត្រូវបានចាត់ទុកថាជាក្រុមរួមតែមួយ ដែលទទួលបានតែមួយភាគបីនៃពេលវេលាដែលមានប៉ុណ្ណោះនោះ[9]។ ក្រុមមេធាវីការពារក្ដីនីមួយៗ តំណាងឲ្យជនជាប់ចោទផ្សេងៗគ្នា និងមានការងារជាអាទិភាព និងផលប្រយោជន៍ផ្សេងៗគ្នា។ ក្រុមមេធាវីការពារក្ដីទាំងនេះមិនមែនជាក្រុមដែលមានសមាសភាពច្រើនហើយមានផលប្រយោជ៍តែមួយឡើយ[10]។ សិទ្ធិជាមូលដ្ឋាន

---

[9] *សូមមើលរឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Kupreškić និងអ្នកផ្សេងទៀត* សំណុំរឿង IT-95-16-T សាលក្រម ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ៣៣៩(ខ)។ "ក្នុងការកំណត់តួនាទីរបស់ជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងត្រូវរក្សាទុកនូវការពិចារណារបស់ខ្លួនជាមុនដូចតទៅ៖ ... (ខ) គោលការណ៍ដែលការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទនីមួយៗ ត្រូវតែពិចារណាដាច់ដោយឡែកពីគ្នា។ បញ្ហាដែលជនជាប់ចោទត្រូវបានជំនុំជម្រះរួមគ្នានោះ មិនមែនមានន័យថា ការចោទប្រកាន់លើពួកគាត់ មិនអាចត្រូវបានទទួលការពិចារណាដាច់ដោយឡែកនោះទេ"។

[10] និយាយអំពីរឿងនេះ វាធ្វើអោយរន្ធត់ញាប់ញ័រទៅដល់សតិសម្បជញ្ញៈ ដែលថាចៅក្រមទាំងឡាយរបស់អង្គជំនុំជម្រះសាលាដំបូង ទាំងចៅក្រមជាតិ និងចៅក្រមអន្តរជាតិ ដែលមានលក្ខណៈសម្បត្តិមកពីប្រព័ន្ធច្បាប់ខំម៉ុនឡ និងស៊ីវិលឡ បានប្រព្រឹត្តនូវទង្វើ ហាក់ដូចជាថា ជនជាប់ចោទទាំងអស់គឺជាក្រុមសមូហភាពមួយ ផ្ទុយពីជនជាប់ចោទម្នាក់ៗដែលត្រូវបានទទួលការការពារក្ដីក្នុងលក្ខណៈដាច់ដោយឡែកពីគ្នា ដែលមានផលប្រយោជន៍ខុសគ្នា និងទីទៃពីគ្នា។ នៅក្នុងអនុស្សារណៈអន្តរការិយាល័យរបស់ អង្គជំនុំជម្រះសាលាដំបូង នាពេលថ្មីៗនេះ ចុះថ្ងៃទី ៣ កុម្ភៈ ២០១១ អង្គជំនុំជម្រះសាលាដំបូង បានថ្លែងថា ក្រុមមេធាវីការពារក្ដី គួរសម្របសម្រួលគ្នានៅក្នុងសំណើសុំរបស់ពួកគេ នៅពេលណាដែលអាចធ្វើបាន ហើយដាក់សំណើសុំរួមគ្នាទៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង ។ *សូមមើល* អនុស្សារណៈអន្តរការិយាល័យ ក្រោមចំណងជើងថា៖ ការជូនដំណឹងជាមុនអំពីការសម្រេចសេចក្ដីរបស់អង្គជំនុំជម្រះទៅលើពាក្យសុំ E14, E15, E9/2, E9/3, E24 and E27ចុះថ្ងៃទី ៣ កុម្ភៈ ២០១១ ទំព័រ ២។

របស់លោក អៀង សារី ក្នុងការការពារខ្លួន និងសិទ្ធិសួរលើសាក្សីដែលប្រឆាំងខ្លួន នឹងមិនត្រូវបាន គោរពនោះទេ ប្រសិនបើពេលវេលាដែលផ្តល់ឱ្យគាត់ ត្រូវបានកំណត់របៀបនេះនោះ[11]។ ដាច់ខាត គេមិនត្រូវអនុញ្ញាតអោយ កសព កាត់បន្ថយសិទ្ធិទាំងឡាយរបស់ជនជាប់ចោទនីមួយៗឡើយ។

**ខ. ការប្រើប្រាស់ចម្លើយរបស់សាក្សីនានា ដោយមិនបានស្តាប់ចម្លើយសាក្សីពាក់ព័ន្ធ**

2. នៅក្នុងកថាខណ្ឌ១០ ក.ស.ព អះអាងថា៖

> បុគ្គលផ្សេងៗទៀត គឺមិនទាន់បានដាក់បញ្ចូលឈ្មោះក្នុងបញ្ជីនៅឡើយទេ ដោយសារផ្អែកលើមូលដ្ឋានថា សហព្រះរាជអាជ្ញានឹងត្រូវបានអនុញ្ញាតឱ្យបញ្ចូលជាភស្តុតាងនូវចម្លើយរបស់សាក្សីនានាព្រមទាំងឯកសារពាក់ព័ន្ធផ្សេងៗអនុលោមតាមវិធាន៨៧ នៃវិធានផ្ទៃក្នុង។ ក្នុងករណីបើសិនជាចម្លើយរបស់សាក្សីនានា និងឯកសារពាក់ព័ន្ធផ្សេងៗមិនត្រូវបានយល់ព្រមទទួលយកទេនោះ សហព្រះរាជអាជ្ញាសូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងឱ្យបានជ្រាបថា ខ្លួនអាចនឹងធ្វើសំណើសុំបន្ថែមទៀតនូវអ្នកជំនាញ សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវកោះហៅឱ្យចូលបង្ហាញខ្លួននៅក្នុងសវនាការ បើសិនជាតាមការយោបល់របស់សហព្រះរាជអាជ្ញាយល់ថា ការដកចេញនូវឯកសារភស្តុតាងបែបនេះ ជាការធ្វើឱ្យខូចដល់លទ្ធភាពរបស់ខ្លួនក្នុងការបំពេញឱ្យបានគ្រប់គ្រាន់ទៅតាមលក្ខខណ្ឌតម្រូវនៃបទដ្ឋានស្តីពីភស្តុតាង លើបញ្ហាទាក់ទងនឹងឯកសារដោយឡែកណាមួយ ក្នុងសំណុំរឿងនេះ។

ហេតុដូចនេះ មេធាវីការពារក្តីជូនដំណឹងអង្គជំនុំជម្រះសាលាដំបូងថា លោក អៀង សារី មានបំណងប្រើប្រាស់សិទ្ធិរបស់ខ្លួន តទល់នឹងសាក្សីទាំងអស់ដែលផ្តល់សក្ខីកម្មប្រឆាំងនឹងរូបគាត់[12]។

---

[11] សិទ្ធិតទល់មានសារៈសំខាន់ចំពោះដំណើរការជំនុំជម្រះក្តីដោយយុត្តិធម៌។*សូមមើល ឧទាហរណ៍ រឿងក្តី Saidi តទល់នឹង France*, តុលាការ ECHR, បណ្តឹងលេខ 14647/89, ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៩៣ កថាខណ្ឌ៤៤។

[12] *សូមមើល* កតិកាសញ្ញាអន្តរជាតិស្តីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា១៤(៣)(ង) ដែល អ.វ.តក ត្រូវគោរពតាមដោយអនុលោមតាមមាត្រា៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ដូចដែលត្រូវបានធ្វើវិសោធនកម្មក្នុងឆ្នាំ១៩៩៩។ “ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ៖... ត្រូវមានការសួរចម្លើយ ឬសុំឱ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុក និងសុំឱ្យសាក្សីដោះបន្ទុកចូលខ្លួន ដើម្បីសួរចម្លើយក្នុងនាមខ្លួន ក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក...។” នៅក្នុងសំណុំរឿងលេខ០០១ អង្គជំនុំជម្រះសាលាដំបូង បដិសេធការទទួលស្គាល់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីពីររូបដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ពីព្រោះសាក្សីបានស្លាប់មុនពេលសវនាការ ហើយ ឌុច មិនមានលទ្ធភាពតទល់ភាពត្រឹមត្រូវនៃចម្លើយរបស់សាក្សីទាំងនោះ” សូមមើលករណី កាំង ហ្គេកអ៊ាវ សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អវតក/អជសង សេចក្តីសម្រេចស្តីពីភាពអាចទទួល

មេធាវីការពារក្ដីនឹងជំទាស់នឹងការប្រើប្រាស់ចម្លើយរបស់សាក្សីណាមួយ ដែលនឹងមិនត្រូវបានកោះហៅឲ្យផ្តល់សក្ខីកម្ម ពោលគឺ មេធាវីការពារក្ដីត្រូវតែអាចពិនិត្យមើលលើភស្តុតាងទាំងអស់ប្រឆាំងនឹងរូបលោក អៀង សារី។ ក.ស.ព គួរតែត្រូវបានតម្រូវឲ្យពិនិត្យមើលឡើងវិញជាបន្ទាន់ចំពោះបញ្ជីឈ្មោះរបស់ខ្លួន និងបញ្ចូលនូវសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញទាំងអស់ ដែល ក.ស.ព មានបំណងចង់បញ្ចូលចម្លើយរបស់អ្នកទាំងនោះ។

**គ. ការស្តាប់ចម្លើយសាក្សីនានា ដែលមានឈ្មោះនៅក្នុងឧបសម្ព័ន្ធ៥**

3. នៅក្នុងកថាខណ្ឌ១១ ក.ស.ព លើកឡើងថា ខ្លួនមិនទាន់បានដាក់បញ្ចូលនូវបុគ្គលទាំងអស់ដែលអាចជួយនៅក្នុងការបញ្ជាក់យថាភូតលើឯកសារពាក់ព័ន្ធ ដែលនឹងត្រូវសុំឲ្យយល់ព្រមទទួលយកនោះទេ។ ក.ស.ព លើកឡើងថា ឧបសម្ព័ន្ធ ៥ មានឈ្មោះបុគ្គលទាំងនេះមួយចំនួន។ ហេតុដូច្នេះ មេធាវីការពារក្តីជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថា មេធាវីការពារក្តីទំនងជាតវ៉ានឹងការបញ្ជាក់យថាភូតលើឯកសារសឹងតែទាំងអស់ ឬទាំងអស់ ដែល កសព សុំឲ្យយល់ព្រមទទួលយកនោះ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងគួរតែកោះហៅសាក្សីនានាដែលមានឈ្មោះនៅក្នុងឧបសម្ព័ន្ធ ៥ ហើយ ក.ស.ព គួរតែតម្រូវឲ្យដាក់សេចក្តីសង្ខេប និងព័ត៌មានបន្ថែមនៃសាក្សីទាំងនេះ ដោយសារតែវាតម្រូវឲ្យធ្វើដូច្នេះចំពោះសាក្សីទាំងអស់ផ្សេងទៀត។

**ឃ. វចនាសម្ព័ន្ធ និងការធ្វើបទបង្ហាញភស្តុតាង**

4. នៅក្នុងកថាខណ្ឌ១៥ ដល់ ២១ ក.ស.ព បានលើកឡើងថា ខ្លួនបានដាក់ជូនសំណើអំពីវចនាសម្ព័ន្ធសម្រាប់ការបង្ហាញខ្លួនអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី នៅពេលសវនាការ ដែលក្នុងនោះបញ្ហាជាគន្លឹះនានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះគួរបានលើកមកបង្ហាញជូន។ "សហព្រះរាជអាជ្ញាស្នើថា សំណើរបស់ខ្លួនសម្រាប់គ្រោងការរួម នៃការធ្វើបទបង្ហាញភស្តុតាងនេះនឹងត្រូវបានរក្សាទុកដើម្បីជាការផ្តល់ជូនដល់អង្គជំនុំជម្រះសាលាដំបូង និងសាធារណជនទូទៅ នូវលទ្ធភាពយល់ដឹងឲ្យបានល្អបំផុតតាមដែលអាចធ្វើទៅបានអំពីសំណុំរឿង និងលើកកំពស់

យកសម្ភារៈដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ ឯកសារE43/4 ERN: 00332849-00332857 កថាខណ្ឌ១៣-១៧។

ប្រសិទ្ធភាពនៅក្នុងបទបង្ហាញរបស់ខ្លួនដោយគូភាគីនានា"[13]។ ក.ស.ព លើកឡើងបន្ថែមថា សាក្សីរបស់មេធាវីការពារក្តី និងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវចូលខ្លួនមកឆ្លើយបំភ្លឺ ដោយផ្អែកតាមរចនាសម្ព័ន្ធដែលស្នើសុំ។ ទោះបីជាមេធាវីការពារក្តីយល់ព្រមជាមួយ ក.ស.ព ថា ក.ស.ព មានបន្ទុកបង្ហាញភស្តុតាងអោយអស់វិមតិសង្ស័យ[14] ក.ស.ព អាចត្រូវបានអនុញ្ញាតឱ្យដាក់តែរចនាសម្ព័ន្ធនៃរឿងក្តីដែលស្នើសុំរបស់ខ្លួន តែក្នុងករណីដែលការជំនុំជម្រះត្រូវបានធ្វើឡើងតាមរបៀបនីតិវិធីចំពោះមុខ និងការដេញដោលដោយគូភាគី ដែលក្នុងនោះភាគីនីមួយៗអាចបង្ហាញរឿងក្តីរបស់ខ្លួន។

5. ប្រសិនបើ ក.ស.ព ត្រូវបានអនុញ្ញាតឱ្យបង្ហាញរឿងក្តីនៅក្នុងរបៀបដែលខ្លួនជ្រើសយក មេធាវីការពារក្តីក៏ត្រូវតែទទួលបានការអនុញ្ញាតបែបនេះដូចគ្នា ក្នុងការបង្ហាញរឿងក្តីរបស់ខ្លួនក្នុងរបៀបដែលខ្លួនជ្រើសយកដែរ ដើម្បីឱ្យស្របតាមគោលការណ៍សមភាពនៃមធ្យោបាយក្នុងការតទល់ក្តី។ ប្រសិនបើមិនមានរឿងក្តីដាច់ដោយឡែករវាង ក.ស.ព និងមេធាវីការពារក្តី អង្គជំនុំជម្រះសាលាដំបូងត្រូវតែរៀបចំរចនាសម្ព័ន្ធនៃការធ្វើបទបង្ហាញរឿងក្តី តាមរបៀបដែលខ្លួនយល់ថាល្អបំផុត ជាជាងគ្រាន់តែទទួលរចនាសម្ព័ន្ធដែលបានលើកឡើងដោយ ក.ស.ព នោះ។

6. ថ្មីៗនេះ មេធាវីការពារក្តីបានដាក់សំណើសុំដែលសមហេតុផល និងយុត្តិធម៌ សម្រាប់កិច្ចដំណើរការជំនុំជម្រះ ដែលអនុញ្ញាតឱ្យ ក.ស.ព ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តី ធ្វើបទបង្ហាញរឿងក្តីរបស់ខ្លួន[15]។ ផ្ទុយទៅវិញ សំណើរបស់ ក.ស.ព មិនបានគោរពឱ្យបានត្រឹមត្រូវចំពោះគោលការណ៍សមភាពនៃមធ្យោបាយក្នុងការតទល់ក្តីនោះទេ។

### ឃ. លទ្ធភាពក្នុងការកោះហៅសាក្សីបន្ថែមក្នុងអំឡុងពេលជំនុំជម្រះ

7. នៅក្នុងកថាខណ្ឌ ១២ ក.ស.ព លើកឡើងថា៖

---

[13] សំណើសុំ កថាខណ្ឌ១៦។

[14] *សូមមើល* សំណើសុំ កថាខណ្ឌ៨។ *ករណីរឿង អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/អជសជ សំណើសុំរបស់ អៀង សារី ឱ្យអង្គបុរេជំនុំជម្រះសាលាដំបូងធ្វើការជំនុំជម្រះលើសំណុំរឿងលេខ០០២ ដោយអនុវត្តតាមវិសោធនកម្មនីតិវិធីដែលបានស្នើសុំ និងសំណើសុំផ្អាកជាបន្ទាន់លើដីកាបង្គាប់ដើម្បីដាក់សម្ភារៈសម្រាប់រៀបចំសវនាការ ចុះថ្ងៃទី២៨ ខែកុម្ភៈឆ្នាំ២០១០ ឯកសារE9/3 ERN: 00640920-00640935។

[15] *ដូចដើងទំព័រខាងលើ* ឧបសម្ព័ន្ធ។

កាលណាអ្នកជំនាញ សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីដែលបានកំណត់អត្តសញ្ញាណនៅក្នុងបញ្ជីឈ្មោះក្នុងឧបសម្ព័ន្ធទាំងនេះ មិនអាចបង្ហាញខ្លួននៅពេលសវនាការបានដោយសារហេតុផលណាមួយក៏ដោយ ឬមួយក៏ពួកគេបានមកបង្ហាញខ្លួននៅពេលសវនាការ តែមិនអាចមានលទ្ធភាពរៀបរាប់ពីអង្គហេតុដែលមាននៅក្នុងចម្លើយជាលាយលក្ខណ៍អក្សររបស់ខ្លួនបាន នោះសហព្រះរាជអាជ្ញាផ្តល់ការជូនដំណឹងផងដែរដល់អង្គជំនុំជម្រះសាលាដំបូងថាខ្លួនអាចស្នើឱ្យសុំកោះហៅអ្នកជំនាញ សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីជំនួស ឱ្យចូលមកបង្ហាញខ្លួនដើម្បីផ្តល់សក្ខីកម្មលើបញ្ហាដូចគ្នា ឬស្រដៀងគ្នានោះ។ ជាទូទៅជាងនេះទៀត នៅពេលដែលសវនាការកំពុងដំណើរការ បើសហព្រះរាជអាជ្ញាជឿជាក់ថាមានការចាំបាច់ត្រូវហៅសាក្សីក្រោយៗឱ្យមកបំភ្លឺ ដែលសហព្រះរាជអាជ្ញាផ្តល់ការជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថាខ្លួននឹងធ្វើសំណើនេះនៅពេលដែលខ្លួនមានការជឿជាក់ដូច្នេះ។

8. វិធាន ក្នុងសំណៅសេចក្តីព្រាងនាពេលបច្ចុប្បន្ន មិនបានចែងអំពីលទ្ធភាពសម្រាប់ឱ្យភាគីមួយកោះហៅសាក្សីបន្ថែម ដែលត្រូវបានដាក់បញ្ចូលនៅក្នុងបញ្ជីសាក្សីរបស់ខ្លួន លុះត្រាតែភាគីដែលស្នើសុំ ត្រូវតែធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថា សក្ខីកម្មដែលបានស្នើសុំនោះ ពុំអាចធ្វើបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ[16]។ ប្រសិនបើ ក.ស.ព ត្រូវបានផ្តល់នូវបុព្វសិទ្ធិបញ្ចូលសាក្សីបន្ថែមទៅក្នុងបញ្ជីសាក្សីរបស់ខ្លួន ដែលសក្ខីកម្មរបស់សាក្សីទាំងនោះអាចធ្វើបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ ដូចនេះមេធាវីការពារក្តីត្រូវតែទទួលបានបុព្វសិទ្ធិដូចគ្នានេះដែរ ដោយផ្អែកតាមគោលការណ៍សមភាពនៃមធ្យោបាយក្នុងការតទល់ក្តី។

## ង. លទ្ធភាពកោះហៅសាក្សីនានា ដែលសហចៅក្រមស៊ើបអង្កេតនៅមិនទាន់បានធ្វើការស្តាប់ចម្លើយ

9. ក.ស.ព លើកឡើងថា ខ្លួនមានបំណងកោះហៅសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលសហចៅក្រមស៊ើបអង្កេតនៅមិនទាន់បានធ្វើការស្តាប់ចម្លើយពីមុនមក។ នៅក្នុងកថាខណ្ឌ១៣ ក.ស.ព លើកឡើងថា៖

> មានបុគ្គលមួយចំនួនតូចប៉ុណ្ណោះ ដែលសហចៅក្រមស៊ើបអង្កេតនៅមិនទាន់បានធ្វើការស្តាប់ចម្លើយ ហើយដែលសហព្រះរាជអាជ្ញាចង់ឱ្យធ្វើការកោះហៅមកនៅចំពោះមុខអង្គជំនុំជម្រះនេះ។ បុគ្គលទាំងនោះរួមមានភាគីច្រើនជាអ្នកជំនាញដែលមាននៅក្នុងបញ្ជីឈ្មោះនៅក្នុង **ឧបសម្ព័ន្ធទី២**។ ជាការជាក់ស្តែង ការិយាល័យសហចៅក្រមស៊ើបអង្កេត មិនបានស្តាប់ចម្លើយបុគ្គលនានាដែលធ្លាប់ត្រូវបានគេដឹងយ៉ាងទូលំទូលាយរួចមកហើយស្តីពីបញ្ហានានា ដែលទាក់ទងនឹងកម្មវត្ថុនៃរឿងក្តីដែលនៅក្នុងដីកាបញ្ជូន

[16] វិធាន៨៧(៤)។

រឿងទៅជំនុំជម្រះ។ ក៏ប៉ុន្តែ ការចុះផ្សាយអំពីបុគ្គលទាំងនេះបែរជាត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងទៅវិញ។ អង្គហេតុដែលថាអ្នកជំនាញ ឬសាក្សី ទាំងនេះមិនបានបង្ហាញសក្ខីកម្មនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត មិនបានកាត់បន្ថយតម្លៃនៃសក្ខីកម្មរបស់ពួកគេទេ។ តាមពិតទៅ បុគ្គលនីមួយៗទាំងនោះគឺស្ថិតនៅក្នុងឋានៈមួយ ដែលអាចផ្ដល់ជូននូវទស្សនៈដែលមានលក្ខណៈទោលបាន (uniques insight) ដែលជាញឹកញាប់ គឺនៅលើបញ្ហានានា យ៉ាងច្រើនដែលជាប់ទាក់ទងសមហេតុផលទៅនឹងសំណុំរឿងនេះ ហើយដែលមានលក្ខណៈច្បាស់លាស់ខ្លីៗ ដែលនាំឱ្យមានការចំណេញដល់ថវិការបស់អង្គជំនុំជម្រះផង។ បន្ថែមលើនេះកាលណាសហព្រះរាជអាជ្ញាបានធ្វើការកោះហៅសាក្សី (**ឧបសម្ព័ន្ធទី៣**) ឬ ដើមបណ្ដឹងរដ្ឋប្បវេណី (**ឧបសម្ព័ន្ធទី៤**) ដែលការិយាល័យសហចៅក្រមស៊ើបអង្កេតមិនទាន់បានស្ដាប់ចម្លើយនោះ គឺសហព្រះរាជអាជ្ញាបានធ្វើយ៉ាងដូច្នេះដោយមានការជឿជាក់ថា សក្ខីកម្មរបស់បុគ្គលទាំងនេះមានលក្ខណៈជាប់ទាក់ទងសមហេតុផលយ៉ាងជាក់លាក់ទៅនឹងការបង្ហាញភស្តុតាង អំពីអង្គហេតុសំខាន់ៗជាគន្លឹះ។

10. ក.ស.ព មិនត្រូវអនុញ្ញាអោយកោះហៅសាក្សី ដែល ក.ស.ច.ស មិនទាន់បានធ្វើការស្ដាប់ចម្លើយក្នុងអំឡុងពេលស៊ើបអង្កេតរបស់តុលាការនោះទេ។ ក.ស.ព មានពេលវេលាជាងបីឆ្នាំ ដែលខ្លួនអាចស្នើសុំទៅក.ស.ច.ស ឱ្យធ្វើការស្ដាប់ចម្លើយអ្នកទាំងនោះក្នុងអំឡុងពេលស៊ើបអង្កេតរបស់តុលាការ[17]។ វាជាការមិនគោរពអំណាចរបស់ ក.ស.ច.ស ក្នុងករណីដែល ក.ស.ព កោះហៅសាក្សី ដែល ក.ស.ច.ស យល់ឃើញថាមិនចាំបាច់ក្នុងការស្ដាប់ចម្លើយនោះ។ វិធានផ្ទៃក្នុងចែងថា អង្គជំនុំជម្រះ "ធ្វើសេចក្ដីសម្រេចដោយផ្អែកលើ<u>ភស្តុតាងដែលមាននៅក្នុងសំណុំរឿង</u> ប្រសិនបើភាគីយកភស្តុតាងទាំងនោះមកដាក់នៅចំពោះមុខអង្គជំនុំជម្រះ ឬប្រសិនបើអង្គជំនុំជម្រះខ្លួនឯងយកភស្តុតាងទាំងនោះមកដាក់នៅចំពោះមុខភាគី" [18]។ នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល "ទោះបីជាតុលាការបង្គាប់ឱ្យសាក្សី ឬភាគីនានា ផ្ដល់សក្ខីកម្ម (ការស្ដាប់ចម្លើយ) <u>ការផ្ដល់សក្ខីកម្មរបស់បុគ្គលទាំងនេះ មិនអាចយកជាភស្តុតាងនោះទេ។ ផ្ទុយទៅវិញ សក្ខីកម្មបែបនេះគឺជាព័ត៌មានបន្ថែមក្នុងការបំភ្លឺភស្តុតាងឯកសារដែលបានចងក្រង</u>"[19]។ សាក្សីថ្មីដែលស្នើសុំមិនអាចជួយដល់

---

[17] វិធាន៥៥(១០)។

[18] វិធាន៨៧(៣) (គូសបញ្ជាក់បន្ថែម)។

[19] សៀវភៅនិពន្ធដោយ Nicolas Marie Kublicki មានចំណងជើងថា *An Overview of the French Legal System from an American Perspective*, 12 B.U. INT"L L.J. ទំព័រ 58, 87 (បោះពុម្ពឆ្នាំ 1994) (គូសបញ្ជាក់បន្ថែម)។

អង្គជំនុំជម្រះសាលាដំបូង ដោយសារតែសាក្សីថ្មីទាំងនេះ មិនបានធ្វើការស្តាប់ចម្លើយ ឬមានឯកសារពាក់ព័ន្ធនានានៅ ក្នុងសំណុំរឿងដែលត្រូវការបំភ្លឺនោះទេ។

11. ទោះបីជាយ៉ាងណាក៏ដោយ អ្នកជំនាញថ្មីដែលត្រូវបានស្នើសុំ គួរត្រូវបានអនុញ្ញាតឲ្យផ្តល់សក្ខីកម្ម (លើកលែងតែអ្នកទាំងនោះមិនមានលក្ខណៈគ្រប់គ្រាន់ជាអ្នកជំនាញ ដែលករណីនេះនឹងត្រូវបានលើកឡើងនៅក្នុងសំណើសុំខាងមុននេះ[20]) ប្រសិនបើអ្នកជំនាញទាំងនេះត្រូវបានកោះហៅមករៀបរាប់ និងបកស្រាយសេចក្តីថ្លែង ដែលមាននៅក្នុងអត្ថបទបោះពុម្ពផ្សាយរបស់ពួកគេ ដែលមាននៅក្នុងសំណុំរឿងរួចហើយនោះ។ ដូចដែល ក.ស.ច.ស លើកឡើងពីមុន "សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ... អាស្រ័យដោយអ្នកខ្លះក្នុងចំណោម [អ្នកជំនាញដែលបានស្នើឡើងទាំង

---

[20] ឧទាហរណ៍ដូចជា Stephen Heder គឺស្ថិតនៅក្នុងបញ្ជីអ្នកជំនាញរបស់ កសព។ លោក Heder ធ្លាប់បានបំរើការងារនៅ កសព ក្នុងការតាក់តែងដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរ ហើយបន្ទាប់មកបានផ្លាស់ប្តូរទៅបំរើការនៅ កសចស ដើម្បីជាជំនួយក្នុងដំណើរការស៊ើបអង្កេតទៅលើដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរដែលគាត់បានជួយក្នុងការតាក់តែងនោះ។ សំខាន់ជាងនេះទៀត លោក Heder ត្រូវបានគេផ្តល់ការងារអោយតាក់តែងការចោទប្រកាន់នានាប្រឆាំងលោក អៀង សារី ហើយបន្ទាប់មកអោយស៊ើបអង្កេតទៅលើការចោទប្រកាន់ដដែលៗទាំងនេះទៀត។ លោក Heder ក៏ជាទីប្រឹក្សាជាន់ខ្ពស់មួយរូបរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាផងដែរ ដែលនេះអាចប៉ះពាល់ដល់ភាពអនាគតិរបស់គាត់ផងដែរ។ ម្យ៉ាងវិញទៀត ជាពិសេសទាក់ទងការបដិសេធរបស់គាត់ក្នុងការឆ្លើយតបទៅនឹងចម្ងល់ទាំងឡាយអំពីសាវតាររបស់គាត់ វាទំនងជាថា លោក Heder ប្រហែលជាអាចធ្លាប់បានបំរើការងារអោយ CIA នៅក្នុងអំឡុងពេលពាក់ព័ន្ធទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលបង្កើតអោយមានទំនាស់ផលប្រយោជន៍។ លើសពីនេះទៀត ធ្លាប់មានការចោទប្រកាន់នានាទាក់ទងនឹងការរៀបចំកិច្ចសន្យារបស់លោក Heder និងកិច្ចប្រឹងប្រែងដែលធ្វើឡើងដោយ សហចៅក្រមស៊ើបអង្កេត Lemonde ដើម្បីអោយលោក Bastin ប្រឌិតការវាយតម្លៃដែលមានប្រយោជន៍ទៅលើការបំពេញការងាររបស់លោក Heder។ *សូមមើល រឿងក្តី អៀង សារី សំណុំរឿង* ០០២/១៩-០៩-២០០៧-អវតក/កសចស សំណើសុំព័ត៌មានទាក់ទងនឹងអត្តិភាពដែលមានសក្តានុពលនៃទំនាស់ផលប្រយោជន៍របស់អ្នកស៊ើបអង្កេតរបស់ កសចស លោក Stephen Heder ចុះថ្ងៃទី ៣០ មករា ២០០៩ ឯកសារលេខ A252, ERN: 00282718-00282722 កថាខណ្ឌ៤។ *សូមមើល រឿងក្តី អៀង សារី សំណុំរឿង* ០០២/១៩-០៩-២០០៧-អវតក/កសចស លិខិតរបស់ កសចស ទៅកាន់ មេធាវីការពារក្តី ទាក់ទងនឹងលិខិតដែលមានចំណងជើងថា សំណើសុំព័ត៌មានទាក់ទងនឹងអត្តិភាពដែលមានសក្តានុពលនៃទំនាស់ផលប្រយោជន៍ របស់អ្នកស៊ើបអង្កេតរបស់ កសចស លោក Stephen Heder ចុះថ្ងៃទី ២៤ មករា ២០០៨ ឯកសារលេខ A121/I, ERN: 00159515-00159516 ទំព័រ ១។ *សូមមើល រឿងក្តី អៀង សារី សំណុំរឿង* ០០២/១៩-០៩-២០០៧-អវតក/កសចស សំណើសុំព័ត៌មានទាក់ទងនឹងអត្តិភាពដែលមានសក្តានុពលនៃទំនាស់ផលប្រយោជន៍របស់អ្នកស៊ើបអង្កេតរបស់ កសចស លោក Stephen Heder ចុះថ្ងៃទី ៣០ មករា ២០០៩ ឯកសារលេខ A252, ERN: 00282718-00282722 ។ *សូមមើល រឿងក្តី អៀង សារី សំណុំរឿង* ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ០៨) សេចក្តីថ្លែងការណ៍ដោយ Wayne Bastin ចុះថ្ងៃទី ២ ធ្នូ ២០០៩ ឯកសារលេខ D263.4 ទំព័រ ១៥។

00642550



នេះ] ដែលបច្ចុប្បន្ន ឬពីមុនជាបុគ្គលិកនៃភាគីមួយនៃរឿងក្ដី (បណ្ឌិត Etcheson និង លោក អៀ ម៉េងទ្រី) ឬជាបុគ្គលិករបស់ ក.ស.ច.ស (បណ្ឌិត Heder) នោះវានឹងមិនមែនជាផលប្រយោជន៍ប្រសើរខាងយុត្តិធម៌ទេ ប្រសិនបើចាត់តាំងពួកគេជាអ្នកជំនាញ ដែលកំណត់ដោយវិធាន ៣១ នៃ វិធានផ្ទៃក្នុង នៅក្នុងដំណាក់កាលនេះ។ ... ក្នុងករណីដែលជនត្រូវចោទណាម្នាក់ត្រូវបានបញ្ជូនទៅជម្រះ នៅក្នុងរឿងក្ដីនេះ អ្នកដែលមានឈ្មោះនៅក្នុងសំណើសុំ នៅតែអាចត្រូវបានកោះហៅឱ្យមកផ្ដល់សក្ខីកម្ម ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថា វាមានប្រយោជន៍ដូច្នេះ"[21]។

II. **សំណើសុំ**

**អាស្រ័យហេតុនេះ** ដោយផ្អែកទៅលើហេតុផលដែលបានបញ្ជាក់ជូនខាងលើ មេធាវីការពារក្ដីសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងបើកសវនាការសួរដេញដោលផ្ទាល់មាត់ដើម្បីពិភាក្សាបញ្ហាផ្សេងៗខាងលើ និងដើម្បីធានាថា សិទ្ធិរបស់លោក អៀង សារី ត្រូវបានគោរពយ៉ាងពេញលេញ ពាក់ព័ន្ធនឹងបញ្ហានីមួយៗដែលបានលើកឡើង។

សូមលោកសហចៅក្រមទទួលយកសំណើសុំនេះដោយក្ដីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ ២០១១

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្ដម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**

[21] *រឿងក្ដី នួន ជា* សំណុំរឿងលេខ០០២/១៩-០៩-២០០៧/កសចស ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំចាត់តាំងអ្នកជំនាញ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ D281/3 ERN: 00464901-00464904 កថាខណ្ឌ៧-៨។